អង្គការអភិវឌ្ឍន៍សំលេងសហគមន៍

**គម្រោង៖** បង្កើនជីវភាពរស់នៅរបស់សហគមន៍ តាមរយៈអេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ

# របាយការណ៍ករណីសិក្សា

## សហគមន៍អេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ – យុវជនក្នុងសហគមន៍

១. សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ថ្ម ត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០៦ ដោយមានការគាំទ្រពីមន្ទីរ និងក្រសួងបរិស្ថាន។ សហគមន៍មានផ្ទៃដី ៥០៦ ហិកតា មានគណៈកម្មការ ៩ រូប (ស្រី ៣ រូប) និងមានអ្នកទទួលផលសរុប ៦២៥ នាក់។ ប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ចិញ្ចឹមសត្វ និងប្រមូលអនុផលព្រៃឈើ ខណៈមួយចំនួនធ្វើការចំណាកស្រុក។

សហគមន៍កំពុងប្រឈមមុខនឹងបញ្ហាខ្វះធនធានថវិកា ដៃគូអភិវឌ្ឍន៍ និងសមត្ថភាពបច្ចេកទេស។ បន្ថែមពីនេះ ភូមិជីពូក និងភូមិងយ រងផលប៉ះពាល់ពីរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ ដែលប៉ះពាល់ដល់ទិន្នផលកសិកម្ម និងជីវភាពរស់នៅ បង្កើនហានិភ័យនៃសកម្មភាពខុសច្បាប់លើធនធានធម្មជាតិ។

## ២.ព័ត៌មានទូទៅអំពីយុវជន យឺន ហៀ មុនចូលរួមជាមួយគម្រោង GEF

យុវជន យឺន ហៀ ភេទស្រី អាយុ ២៥ ឆ្នាំ រស់នៅភូមិជីពូក ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ នាងមានមុខរបរជាកសិករ ហើយបានចូលរួមសកម្មភាពជាមួយសហគមន៍ព្រៃធំអន្លង់ថ្ម ក្នុងឆ្នាំ ២០២៤។ មូលហេតុដែលនាងសម្រេចចិត្តចូលរួមជាមួយសហគមន៍ គឺដោយសារតែនាងស្រឡាញ់ព្រៃឈើ ប៉ុន្តែមិនទាន់មានការយល់ដឹងស៊ីជម្រៅ ជាពិសេសអំពីសារៈប្រយោជន៍នៃធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ។ នាងមានបំណងចូលរួមកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ ថែរក្សាព្រៃឈើ និង

ទាក់ទាញភ្ញៀវទេសចរណ៍ឱ្យមកទស្សនា។  នៅពេលនោះនាងមានការយល់ដឹងតិចតួចអំពីអត្ថប្រយោជន៍នៃការការពារធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ហើយមិនទាន់មានទំនុកចិត្តគ្រប់គ្រាន់ក្នុងការនិយាយផ្សព្វផ្សាយដល់សមាជិកសហគមន៍ និងយុវជនផ្សេងទៀតឡើយ។



## ៣.ក្នុងអំឡុងពេលចូលរួមសកម្មភាពជាមួយគម្រោង GEF

ក្នុងឆ្នាំ ២០២៤ សហគមន៍ព្រៃធំអន្លង់ថ្ម បានទទួលការគាំទ្រពីគម្រោងកម្មវិធី GEF ដែលជាឱកាសល្អសម្រាប់យុវជន យឺន ហៀ ក្នុងការទទួលបានចំណេះដឹង និងជំនាញថ្មីៗ។ នាងបានទទួលការបណ្តុះ

បណ្តាលអំពីបច្ចេកទេសដាំដំណាំ ការធ្វើជីកំប៉ុស្ត និងទទួលបានផ្នើសម្រាប់ដាំដំណាំ និងប្រធានបទការបម្រែបម្រួលអាកាសធាតុ តាមរយៈការគាំទ្រពីអង្គការអភិវឌ្ឍន៍សំឡេងសហគមន៍ (BCV)។ ក្រៅពីការបណ្តុះបណ្តាល នាងបានចូលរួមសកម្មភាពជាច្រើនជាមួយសហគមន៍ ដូចជា៖ ចុះល្បាតព្រៃ ដើម្បីទប់ស្កាត់បទល្មើសកាប់ឈើ ចូលរួមដាំកូនឈើ ចូលរួមធ្វើផ្លូវការពារភ្លើងឆេះព្រៃ សម្អាត និងត្រួសត្រាយផ្លូវសម្រាប់ភ្ញៀវទេសចរណ៍ដើរទស្សនាព្រៃសហគមន៍ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការប្រែប្រួលអាកាសធាតុ និងសារៈប្រយោជន៍នៃការអភិរក្សធនធានធម្មជាតិ លើសពីនេះ នាងក៏បានចូលរួមជាមួយក្រុមសន្សំប្រាក់សហគមន៍ផងដែរ។





## ៤. ការប្រែប្រួលរបស់យុវជន យឺន ហៀ បន្ទាប់ពីចូលរួមជាមួយគម្រោង GEF

តាមរយៈការទទួលបានការកសាងសមត្ថភាព ចំណេះដឹង និងជំនាញពីគម្រោង GEF យុវជន យឺន ហៀ មានការរីកចម្រើនជាច្រើន។ នាងមានទំនុកចិត្តកាន់តែខ្លាំងក្នុងការផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ និងការការពារធនធានធម្មជាតិដល់ប្រជាពលរដ្ឋក្នុងសហគមន៍ នាងអាចគៀគរប្រជាពលរដ្ឋជាពិសេសយុវជនក្នុងសហគមន៍ ឱ្យចូលរួមសកម្មភាពអភិរក្ស និងអភិវឌ្ឍសហគមន៍បានកាន់តែប្រសើរឡើង។

**សម្រង់សម្តីយុវជន យឺន ហៀ:** "ការចូលរួមជាមួយគម្រោង GEF បានធ្វើឱ្យខ្ញុំមានចំណេះដឹង និងជំនាញថ្មីៗ ទាំងផ្នែកកសិកម្ម និងការអភិរក្សធនធានធម្មជាតិ។ ខ្ញុំមានទំនុកចិត្តកាន់តែខ្លាំងក្នុងការនិយាយ និងផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុទៅកាន់ប្រជាពលរដ្ឋក្នុងសហគមន៍។ ខ្ញុំមានមោទនភាពដែលបានចូលរួមថែរក្សាព្រៃឈើ និងជួយអភិវឌ្ឍសហគមន៍របស់យើងឱ្យកាន់តែប្រសើរឡើង។"

**សំណូមពរ និងអនុសាសន៍:** ដោយការទទួលបានការគាំទ្រពីគម្រោង GEF មានរយៈពេលខ្លី ទើបបានជាងឆ្នាំ នាងស្នើសុំគម្រោង GEF បន្តគាំទ្រការបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់យុវជន និងស្ត្រីក្នុងសហគមន៍ បង្កើនការគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈសម្រាប់សកម្មភាពអភិរក្ស និងកសិកម្មដើម្បីលើកកម្ពស់ឱកាសចូលរួមរបស់យុវជនក្នុងការគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ និងជាពិសេសសូមបន្តគាំទ្រក្រុមសន្សំប្រាក់ ដើម្បីជួយលើកកម្ពស់ជីវភាពគ្រួសារអោយកាន់តែល្អប្រសើ។

**រៀបចំដោយ៖ លោកស្រី ជួប ចន្ទី** ក្រុមអ្នកវាយតម្លៃឯករាជ្យ ART